**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**
សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៤៧៥ អ.ក
ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១
សាលក្រមព្រហ្មទណ្ឌលេខ៖ ៩០ "ន"
ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្តកណ្ដាលនាថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ០៨ និង ៣០ នាទីព្រឹក ដោយមានសមាសភាពដូចតទៅ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សា
លោក [redacted]ៅក្រុមប្រឹក្សា
លោក [redacted] ចៅក្រុមប្រឹក្សា

### តំណាងអយ្យការ

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ៤៧៥ អ.ក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ណែត ភេទប្រុស អាយុ១៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កម្មករសំណង់ ទីកន្លែងកំណើត[redacted] ខេត្តព្រៃវែង និងទីលំនៅបច្ចុប្បន្នភូមិព្រែកសំរោង២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ឪពុកឈ្មោះ[redacted]ស៊ា (រស់) ម្ដាយឈ្មោះ [redacted] ច្រឹប (រស់) ជាអនីតិជន នៅលីវ។ (ឃុំខ្លួនថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១)

២-ឈ្មោះ [redacted]ស ភេទស្រី អាយុ៣០ឆ្នាំ ទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តកណ្ដាល។ (គេចខ្លួន)

ជាប់ចោទពីបទ: "ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

មានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ណែត។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៖ ៩៦០ ដកសព/២១ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៖ ១០៦៤ ដកជរ/២១ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល។

-បានឃើញ ដីកាចាត់តាំងប្រធានក្រុមប្រឹក្សាជំនុំជំរះលេខ៖ ១០៧៣ ដកចត/២១ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តកណ្ដាល។



Scanned with CamScanner

## អង្គហេតុមានដូចតទៅ៖

កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១០ និង ១០ នាទីព្រឹក មានជនសង្ស័យឈ្មោះ[redacted] ណែត បានទិញថ្នាំញៀនប្រភេទម៉ាទឹកកកចំនួន ០៤កញ្ចប់ ពីឈ្មោះ[redacted]ស ដែលជាអ្នកជួញដូរថ្នាំញៀននៅចំណុចទំនប់ផ្កែផ្កូត ស្ថិតនៅភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល ដើម្បីយកមកធ្វើការលក់ដូរបន្ត ហើយក៏ត្រូវសមត្ថកិច្ចចុះមកធ្វើការបង្ក្រាបចាប់បានជនសង្ស័យឈ្មោះ [redacted] ណែត ដោយបានដកហូតថ្នាំញៀនចំនួន ១៤កញ្ចប់ ស្មើរនឹង ០,៨៥ក្រាម។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ណែត បានឆ្លើយសារភាពថា៖ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ៩ព្រឹក ខ្លួនបានទៅទិញថ្នាំញៀននៅភូមិព្រែកហូរលិចចំនួន ១៤កញ្ចប់ ក្នុងតម្លៃ ៧០,០០០(ប្រាំពីរម៉ឺន)រៀល ពីឈ្មោះ [redacted] ស ភេទស្រី អាយុ៣០ឆ្នាំ។ ខ្លួនទិញថ្នាំញៀនយកមកទុកជក់ខ្លះ និងខ្លះទៀតទុកលក់បន្ត ដោយខ្លួនលក់ថ្នាំញៀនក្នុងមួយកញ្ចប់តូចតម្លៃ ១០,០០០ (មួយម៉ឺន)រៀល។ ថ្នាំញៀនដែលខ្លួនបានទិញពីឈ្មោះ [redacted] ស ចំនួន១៤កញ្ចប់ គឺខ្លួនលក់ពី៣-៤ថ្ងៃទើបអស់ និងបានប្រាក់ចំណេញ ៧០,០០០(ប្រាំពីរម៉ឺន)រៀល។ ខ្លួនទើបតែចេះជួញដូរថ្នាំញៀនរយៈពេលប្រហែល១ខែប៉ុណ្ណោះ។

-<u>ក្រឡាបញ្ជីអាន</u>៖ឯកសារនានាក្នុងសំណុំរឿង។

-<u>សិទ្ធិនិយាយស្ដីរបស់ភាគីបន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល</u>

ការកត់សំគាល់របស់ជនជាប់ចោទ៖ សូមឱ្យតុលាការបន្ធូរបន្ថយទោសអោយខ្ញុំបាទផង។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ ជនជាប់ចោទឈ្មោះ [redacted] ណែត បានឆ្លើយសារភាពទទួលស្គាល់នូវអំពើប្រព្រឹត្តរបស់ខ្លួន ដូច្នេះតំណាងអយ្យការសូមរក្សាការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ៩៦០ ដកសព/២១ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ ទុកជាបានការដដែល និងប្ដឹងសុំឱ្យតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋានថា៖ ក្រោយពីបានជាប់ពន្ធនាគារមួយរយៈកូនក្ដីរបស់ខ្លួនសន្យាថានឹងកែប្រែខ្លួនជាថ្មី ម្យ៉ាងទៀតកូនក្ដីរបស់ខ្លួនជាអនីតិជនដែលមានអាយុទើបតែ ១៦ឆ្នាំ។ ហេតុនេះស្នើសុំតុលាការសម្រេចផ្ដន្ទាទោសកូនក្ដីរបស់ខ្លួនដោយផ្អែកទៅតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ឡើងទៅ។

## ផ្អែកតាមកិច្ចពិភាក្សាដេញដោល

-ក្រោយពីបានស្ដាប់ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ[redacted] ណែត។

-ក្រោយពីបានពិនិត្យឯកសារនានាកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌។

-ក្រោយពីបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ណែត។

-ក្រោយពីបានពិនិត្យពិចារណា និងពិភាក្សាក្រុមប្រឹក្សាត្រឹមត្រូវតាមច្បាប់។

## សំអាងហេតុ

## តុលាការយល់ឃើញថា៖

១-កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១០ និង ១០ នាទីព្រឹក នៅភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល មានករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បង្កឡើងដោយជនជាប់ចោទឈ្មោះ[redacted] ណែត និងឈ្មោះ[redacted]ស ពិតប្រាកដមែន។



Scanned with CamScanner

២-ជនជាប់ចោទឈ្មោះ [redacted] ណែត ពេលសវនាការបានឆ្លើយសារភាពថា៖ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ៩ព្រឹក ខ្លួនបានទៅទិញថ្នាំញៀនម្តុំភូមិព្រែកហូរលិចចំនួន ១៤កញ្ចប់ ក្នុងតម្លៃ ៧០,០០០(ប្រាំពីរម៉ឺន)រៀល ពីឈ្មោះ [redacted] ស ។ ខ្លួនទិញថ្នាំញៀនយកមកទុកជក់ខ្លះ និងខ្លះទៀតទុកលក់បន្ត ដើម្បីទទួលបានប្រាក់ចំណេញ។ ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ណែត មានភាពស៊ីសង្វាក់គ្នាជាមួយនឹងរបាយការណ៍បញ្ជាក់រឿងហេតុលេខ ៧៣/២០២១ របក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១ របស់អធិការនគរបាលក្រុងតាខ្មៅ ដែលអាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] ណែត និងឈ្មោះ [redacted] ស ពិតជាបានជួញដូរដោយខុសច្បាប់នូវសារធាតុញៀនពិតប្រាកដមែន។

៣-ជនជាប់ចោទឈ្មោះ [redacted] ស អវត្តមាន ពុំមានចម្លើយនៅក្នុងសំណុំរឿងទេ ប៉ុន្តែបើផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ណែត បញ្ជាក់ថា នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ៩ព្រឹក ខ្លួនបានទៅទិញថ្នាំញៀនម្តុំភូមិព្រែកហូរលិចចំនួន ១៤កញ្ចប់ ក្នុងតម្លៃ ៧០,០០០(ប្រាំពីរម៉ឺន)រៀល ពីឈ្មោះ [redacted] ស ភេទស្រី អាយុ៣០ឆ្នាំ ដើម្បីយកមកលក់បន្ត។ ចម្លើយនេះ អាចបញ្ជាក់បានថាឈ្មោះ [redacted] ស ពិតជាអ្នកជួញដូរដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន។

៤-តាមកំណត់ហេតុធ្វើតេស្តបឋម និងវេចខ្ចប់វត្ថុតាង ជាលទ្ធផលដែលបានមកពីការប្រតិកម្មរបស់ឧបករណ៍ពិសោធន៍ប្រភេទ Marquis Test បានបង្ហាញវត្ថុមានជាសារធាតុ មេតំហ្វេតាមីន។ ដំណើរការថ្លឹង និងវេចខ្ចប់ ត្រូវបានធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ និងជនជាប់ចោទឈ្មោះ [redacted] ណែត ថ្លឹងដោយជញ្ជីងម៉ាក Pehtect សរុបចំនួន ១៤កញ្ចប់ ស្មើទម្ងន់ ០,៨៥ ក្រាម។

៥-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ណែត និងឈ្មោះ [redacted] ស មានចេតនាទុច្ចរិតក្នុងការយកសារធាតុញៀនទៅលក់បន្តដើម្បីទទួលបានប្រាក់កម្រៃ គឺជាបទល្មើសព្រហ្មទណ្ឌ បទ: “ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន” ប្រព្រឹត្តនៅភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៦-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ បានប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ណែត និងឈ្មោះ [redacted] ស ពីបទ“ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន” ឃើញថាមានលក្ខណៈត្រឹមត្រូវតាមច្បាប់ តុលាការនឹងពិចារណា ការប្តឹងសុំនេះ។

៧-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើការសន្និដ្ឋានថា៖ ស្នើសុំតុលាការសម្រេចផ្តន្ទាទោសកូនក្តីរបស់ខ្លួន ដោយផ្អែកទៅតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ឡើងទៅ។ តុលាការពិចារណាឃើញថា សេចក្តីសន្និដ្ឋាននេះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីតុលាការពិចារណា។

៨-ជនជាប់ចោទឈ្មោះ [redacted] ណែត និងឈ្មោះ [redacted] ស ជាអនីតិជន និងជានីតិជនមានស្មារតីគ្រប់គ្រាន់អាចទទួលខុសត្រូវនូវអំពើប្រព្រឹត្តរបស់ខ្លួន។

៩-ក្រោយពីបានពិនិត្យ និងពិចារណាលើភស្តុតាង និងរាល់សេចក្តីសន្និដ្ឋានរបស់ភាគី តុលាការប្រកាសថាមានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ណែត និងឈ្មោះ [redacted] ស ពីបទ “ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន” ប្រព្រឹត្តនៅភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១០-អំពីដែលជនជាប់ចោទឈ្មោះ [redacted] ណែត និងឈ្មោះ [redacted] ស ប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សុខភាពអ្នកដទៃ ប៉ះពាល់ដល់របៀបរៀបរយ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម និងច្បាប់របស់រដ្ឋ។



Scanned with CamScanner

១១-ជនជាប់ចោទឈ្មោះ [redacted] ណែត ជាអនីតិជន ដូច្នេះគប្បីតុលាការសម្រេចផ្តន្ទាទោស ដោយអនុវត្តតាមមាត្រា ១៦០ ចំណុចទី១ និងចំណុចទី៣ នៃក្រមព្រហ្មទណ្ឌ។

១២-វត្ថុចាប់យក៖ម្សៅក្រាមពណ៌សថ្លាសង្ស័យជាសារធាតុញៀនម៉ាទឹកកកចំនួន ១៤កញ្ចប់តូច ទម្ងន់ ០,៨៥ ក្រាម និងកាបូបសំរាប់ដាក់លុយចំនួន០១កញ្ចប់ ពណ៌ស្វាយកូឡា(គ្មានលុយ) គប្បីសម្រេចរឹបអូស និងបំផ្លាញចោល តាមមាត្រា៨៤ និងមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៣-ក្រោយពេលប្រព្រឹត្តបទល្មើសរួចជនជាប់ចោទឈ្មោះ [redacted] ស បានរត់គេចខ្លួនបាត់។ ដូច្នេះ គប្បីតុលាការចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] ស តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសលើជនជាប់ចោទ៖

ក-ឈ្មោះ [redacted] ណែត ភេទប្រុស អាយុ១៦ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០១ (មួយ) ឆ្នាំ ០៦(ប្រាំមួយ)ខែ។

ខ-ឈ្មោះ [redacted] ស ភេទស្រី អាយុ៣០ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៣ (បី)ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួនបាន។

ពីបទ៖"ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-វត្ថុចាប់យក៖ម្សៅក្រាមពណ៌សថ្លាសង្ស័យជាសារធាតុញៀនម៉ាទឹកកកចំនួន ១៤កញ្ចប់តូច ទម្ងន់ ០,៨៥ ក្រាម និងកាបូបសំរាប់ដាក់លុយ ចំនួន០១កញ្ចប់ ពណ៌ស្វាយកូឡា(គ្មានលុយ) សម្រេចរឹបអូស និងបំផ្លាញចោល តាមមាត្រា៨៤ និងមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-បង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] ស ភេទស្រី អាយុ៣០ឆ្នាំ សញ្ជាតិខ្មែរ តាមមាត្រា ៣៥៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ណែត និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ស។

-រក្សាសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

| បានឃើញ | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម |
|---|---|
| ថ្ងៃព្រហស្បតិ៍ ១៣កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ | ថ្ងៃព្រហស្បតិ៍ ១៣កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦ |
| កណ្តាល, ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ | កណ្តាល, ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ |
| ប្រធានក្រុមប្រឹក្សា | ក្រឡាបញ្ជីសវនាការ |
| [redacted] | [redacted] |



Scanned with CamScanner